- ចូលរួមនិងរៀបចំធ្វើបទបង្ហាញ ការត្រួតពិនិត្យគោលនយោបាយ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍនៅក្នុងសន្និសីទជាតិ ដើម្បីទទួលបានការគាំទ្រពីស្ថាប័នពាក់ព័ន្ធនានា

- សម្របសម្រួល និងសហការជាមួយគណៈកម្មការនៃរដ្ឋសភានិងព្រឹទ្ធសភាក្នុងក្របខ័ណ្ឌជាតិអំពីបញ្ហាប្រជាជននិងការអភិវឌ្ឍ ដើម្បីជាជំនួយក្នុងការសម្រេចគោលដៅ កម្មវិធី គោលនយោបាយរបស់រាជរដ្ឋាភិបាល
- ចូលរួមក្នុងសន្និសីទនិងកិច្ចប្រជុំជាតិនិងអន្តរជាតិ និងសហការរៀបចំឯកសារសំខាន់ៗស្តីពី បញ្ហាប្រជាជននិងការអភិវឌ្ឍ
- រៀបចំពិធីសារ សេចក្តីប្រកាស និង ដំណោះស្រាយនានាពាក់ព័ន្ធនឹងបញ្ហាប្រជាជនដូចជាសុខភាពបន្តពូជ មនុស្សចាស់ និងយេនឌ័រជាដើម
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ១០.-**

នាយកដ្ឋានបណ្តុះបណ្តាល និងការអភិវឌ្ឍ មានភារកិច្ចដូចតទៅៈ

- ចូលរួមនិងរៀបចំវគ្គបណ្តុះបណ្តាលជូនដល់អ្នកធ្វើគោលនយោបាយ អ្នកធ្វើការសម្រេចចិត្ត និងអ្នកធ្វើផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីបញ្ជ្រាបនិងបង្កើនចំណេះដឹង និងស្វែងយល់អំពីទំនាក់ទំនងរវាងបញ្ហាប្រជាជននិងការអភិវឌ្ឍ
- រៀបចំកម្មវិធីបណ្តុះបណ្តាល ដើម្បីបង្កើតយន្តការផ្លាស់ប្តូរបទពិសោធន៍ និងទស្សនៈជាវិជ្ជមាននិងកម្មវិធីថ្មីៗដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍក្នុងតំបន់ក៏ដូចជាក្រៅតំបន់
- បណ្តុះបណ្តាលបច្ចេកទេស និងចំណេះដឹងក្នុងការវិភាគ ត្រួតពិនិត្យតាមដាន និងមានលទ្ធភាពវាយតម្លៃនូវរាល់បញ្ហាដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍ តាមរយៈការចូលរួមនិងផ្តល់សិក្ខាសាលាថ្នាក់ជាតិនិងអន្តរជាតិ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ១១.-**

នាយកដ្ឋានវិភាគគោលនយោបាយប្រជាជន មានភារកិច្ចដូចតទៅៈ

- ស្រាវជ្រាវពីបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍជូនរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននិងអង្គភាពពាក់ព័ន្ធនានា
- ពិនិត្យ និងស្រាវជ្រាវពីគម្លាតខុសគ្នារវាងទិន្នន័យនិងទិដ្ឋភាពជាក់ស្តែង និងពង្រឹងសមត្ថភាពក្នុងការស្រាវជ្រាវអំពីបញ្ហានានានៅក្នុងគោលនយោបាយជាតិប្រជាជន និង គោលនយោបាយពាក់ព័ន្ធនានាដែលកើតមានឡើងដូចជាការបំលាស់ទី មនុស្សចាស់ នគរូបនីយកម្មជាដើម។

- រៀបចំសូចនាករណ៍សម្រាប់ការអនុវត្តគោលនយោបាយជាតិប្រជាជន ដែលបានកំណត់នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
- អភិវឌ្ឍមជ្ឈមណ្ឌលប្រមូលផ្តុំព័ត៌មាននិងទិន្នន័យទាំងឡាយណាដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ១២.-**

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ មានភារកិច្ចដូចតទៅ:

- កំណត់សូចនាករណ៍ ស្រាវជ្រាវ និងអង្កេតអំពីសហគមន៍ក្រីក្រនៅរាជធានី ខេត្ត ក្រុង
- សម្របសម្រួល និងធ្វើការសហការជាមួយរដ្ឋបាលមូលដ្ឋានក្នុងការកំណត់ឱ្យបាននូវសហគមន៍ក្រីក្រដែលត្រូវការកែលំអ និងអភិវឌ្ឍ
- ស្វែងរកមូលនិធិជាតិនិងអន្តរជាតិ ដើម្បីបង្កើតជាទុនសម្រាប់ការធ្វើឥណទានដល់ប្រជាជនរស់នៅសហគមន៍ក្រីក្រ
- ជំរុញការសន្សំប្រាក់ និងផ្តល់ឥណទានមានការប្រាក់ទាបដល់សហគមន៍តាមតម្រូវការជាក់ស្តែង
- រៀបចំ ចងក្រងនិងកែលំអសហគមន៍ក្រីក្រឱ្យសម្រេចបានតាមគោលការណ៍ និងគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា "១០០ សហគមន៍ក្នុងមួយឆ្នាំ"
- រៀបចំចងក្រងនិងពង្រឹងសមត្ថភាពសហគមន៍
- ពង្រឹងភាពជាដៃគូ ក្នុងសហគមន៍នៅថ្នាក់មូលដ្ឋាន តំបន់ ជាតិ និង អន្តរជាតិ
- រៀបចំ និង ជម្រុញឱ្យមានការផ្លាស់ប្តូរនិងដកស្រង់យកបទពិសោធន៍ល្អៗពីសហគមន៍មួយទៅសហគមន៍មួយទៀតតាមរយៈទស្សនៈកិច្ចសិក្សា និងកិច្ចប្រជុំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា១៣.-**

អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រជាជននិងការអភិវឌ្ឍ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិប្រជាជននិងការអភិវឌ្ឍ រដ្ឋលេធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តន៍ អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦៨១ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តតាកែវ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **សោ សុភាព** សប្បុរសជន នៅស្រុកកោះអណ្តែត ខេត្តតាកែវ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាង ផ្លូវថ្នល់ សាលារៀន និង សមិទ្ធផលផ្សេងៗទៀត នៅឃុំព្រៃយុថ្កា ស្រុកកោះអណ្តែត ខេត្តតាកែវ ចំណាយអស់ទឹកប្រាក់ចំនួន ១៤.៤៧៨ ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន នៃអង្គការ Good Earth Japan (GEJ) ចំនួន ០៤រូប ដែលបានបរិច្ចាគថវិកា ជួយសាងសង់អាគារសិក្សា ចំនួន០១ ខ្នង ដោយមានបំពាក់គ្រឿងសង្ហារឹមគ្រប់ប្រភេទ រួមទាំងរបង ខ្លោងទ្វារ អណ្តូងទឹក ដងទង់ជាតិ និង បង្គន់អនាម័យផង ជូនប្រជាពលរដ្ឋនៅភូមិឫស្សីរោទិ៍ ឃុំតាក្រាម ស្រុកបាណន់ ខេត្តបាត់ដំបង ចំណាយអស់ទឹកប្រាក់សរុបចំនួន ៧៥.២៥០ ដុល្លារអាមេរិក ដូចមានរាយនាម ខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១- | លោក | Helmut | Kiesel | ប្រធានក្រុមហ៊ុន Kiesel |
| ២- | លោក | Hira | Oka | តំណាងក្រុមហ៊ុន HITACHI HQ Tokyo ជប៉ុន |
| ៣- | លោក | Masahiro | Yasuda | នាយកអង្គការ GEJ ប្រចាំកម្ពុជា |
| ៤- | លោក | Peter | Willer | ប្រធានគំរោងកម្មវិធី ជំនួយអាល្លឺម៉ង់ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ HR

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦៥៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

### សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០២រូប ដែលបានសហការល្អជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងបានឧបត្ថម្ភថវិកាជួយរៀបចំបណ្តាញអគ្គិសនីថ្មី ព្រមទាំងប្រគល់វត្ថុបុរាណជូនសារមន្ទីរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយសហមេត្រី ថ្នាក់ សេនា :**

-លោក **ឌូក្លាស អេ.ចេ ឡាតហ្វដ** (**Mr. Douglas A.J. Latchford**)

**ខ.មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ :**

-លោកស្រី **ដូរីស ទេន័រ** (**Mrs. Doris Wiener**)

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៨៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកំពង់ចាម

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេនព្រះសង្ឃ ចំនួន ០១អង្គ និងជូននាយនគរបាលជាតិ ចំនួន ០៦រូប ដែលមានស្នាព្រះហស្ត និងស្នាដៃល្អ ក្នុងការជួយកសាង អភិវឌ្ឍន៍មូលដ្ឋាន នៅស្រុកជើងព្រៃ ខេត្តកំពង់ចាម ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១- | ព្រះគ្រូមុនីជោតោ | **ជួប** | **ជឿន** | ចៅអធិការវត្តពោធិវង្ស ឃុំខ្នុរដំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម |
| ២- | លោកវរសេនីយ៍ឯក | **ខឹម** | **សុវណ្ណវុធ** | អត្តលេខ ០៩៥៥ អនុប្រធានវិទ្យាដ្ឋានបណ្ឌិតសភានគរបាលកម្ពុជា |
| ៣- | លោកវរសេនីយ៍ឯក | **ឆយ** | **ឈឿង** | អត្តលេខ ០៨០៧ អនុប្រធានវិទ្យាដ្ឋានបណ្ឌិតសភានគរបាលកម្ពុជា |
| ៤- | លោកវរសេនីយ៍ឯក | **នួន** | **វិទ្យាស័ក** | អត្តលេខ ០៨៥៧ អនុប្រធានវិទ្យាដ្ឋានបណ្ឌិតសភានគរបាលកម្ពុជា |
| ៥- | លោកវរសេនីយ៍ទោ | **ភុយ** | **សុភា** | អត្តលេខ ០១៧៥៣ ប្រធានការិយាល័យបណ្តុះបណ្តាល នៃស្នងការនគរបាលខេត្តកំពង់ចាម |
| ៦- | លោកវរសេនីយ៍ទោ | **ប៊ិត** | **ផល្លី** | អត្តលេខ ០៣២១៤ អនុប្រធានការិយាល័យកណ្តាលនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម |
| ៧- | លោកវរសេនីយ៍ត្រី | **អ៊ឹម** | **យ៉ុន** | អត្តលេខ ០៤១១៨ អធិការនគរបាលស្រុកបាធាយ ខេត្តកំពង់ចាម |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៨៥ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកំពង់ចាម

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនសប្បុរសជន មន្ត្រីមូលដ្ឋាន និងគណៈកម្មការវត្ត ចំនួន ០៧រូប ដែលមានស្នាដៃល្អ ក្នុងការជួយកសាងសមិទ្ធផលសាធារណៈផ្សេងៗ នៅវត្តពោធិវង្ស ក្នុងឃុំខ្នុរដំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | **ហេង** | **ហុង** | អាចារ្យ | វត្តពោធិវង្ស |
| ២- | លោក | **ទ្រឹង** | **ឈន** | គណៈកម្មការ | វត្តពោធិវង្ស |
| ៣- | លោក | **ជីវ** | **ស៊ាន** | គណៈកម្មការ | វត្តពោធិវង្ស |
| ៤- | លោក | **ទឹម** | **សាត** | ជំទប់ទី២ | ឃុំខ្នុរដំបង |
| ៥- | លោក | **អ៊ុច** | **សារឿន** | មេភូមិ | រវៀង |
| ៦- | លោក | **ឆាំង** | **សេង** | សប្បុរសជននៅប្រទេសអូស្ត្រាលី | |
| ៧- | អ្នកស្រី | **ធា** | **អាំមួយ** | សប្បុរសជននៅប្រទេសអូស្ត្រាលី | |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៧៦.អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

### សម្រេច

**មាត្រា ១** : តែងតាំងមន្ត្រីរាជការចំនួន ១២ រូប ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម ÷

- លោក **កែវ ម៉ុន**
- លោក **យឹម សុន**
- លោក **យូ ឡាណា**
- លោក **អ៊ិត ឡៅ**
- លោក **ជាម ចាន់ថន**
- លោក **ថាច់ វណ្ណី**
- លោក **នូ សុភខន**
- លោក **សេង ប៊ុណ្ណារ៉ា**
- លោក **សេង សុធី**
- លោកស្រី **ខ៉ាន់ យូនារី**
- លោកស្រី **ហ៊ី ម៉ារីណា**
- លោកស្រី **សោម សេរីវឌ្ឍន៍**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៦៧៣ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៨៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

## សម្រេច

**មាត្រា ១** : តែងតាំងមន្ត្រីរាជការចំនួន ០៨ រូប ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម ÷

- លោក **ហួ គីមហួត**
- លោក **សុខ ឡុង**
- លោក **គៀង វឌ្ឍនៈ**
- លោក **នេត សុផាន់ណា**
- លោក **លឹម សាយ**
- លោក **អ៊ុយ សំអុន**
- លោកស្រី **ជា សុម៉ាលី**
- លោកស្រី **ហួន ចំន្ទបូរ៉ា**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៧៥.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១ :** បំពាក់មេដាយ **សុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **លី វណ្ណារ៉ា** ដែលមានស្នាដៃល្អ និងគុណបំណាច់ក្នុងការចូលរួមជួយកសាង និងអភិវឌ្ឍន៍ប្រទេសដោយបានបរិច្ចាគធនធានផ្ទាល់ខ្លួន ដើម្បីជួយស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធ លើវិស័យអប់រំ វប្បធម៌ សង្គម និងព្រះពុទ្ធសាសនា ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និងមាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៨៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន

**ស ម្រេ ច**

**មាត្រា ១** : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ទូច លាង** ក្រមការដើមខ្សែថ្នាក់លេខ៨ ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា ក្រសួងព័ត៌មាន ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧០ អនក្រ-បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

# សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **គួន ម៉ុនធឿន** មន្ត្រីបច្ចេកទេសជាន់ខ្ពស់ថ្នាក់លេខ ៩ ឱ្យបំពេញមុខងារជាប្រធានមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស នៃក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ២៧១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ស្រី ចាន់ថន** តំណាងក្រុមហ៊ុន 7NG និងជាអតីតនិស្សិត មហាវិទ្យាល័យកសិកម្ម ដែលបានជួយឧបត្ថម្ភគាំទ្រ ដល់ការបណ្តុះបណ្តាលធនធានមនុស្សនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម រួមមានផ្តល់ម៉ាស៊ីនកុំព្យូទ័រចំនួន ២០គ្រឿង និងម៉ាស៊ីនបញ្ចាំង LCD ចំនួន ០២គ្រឿង មានតំម្លៃជាទឹកប្រាក់សរុបចំនួន 13.500 ដុល្លារអាមេរិក។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៣៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនទីប្រឹក្សា និងអ្នកជំនាញការបរទេសចំនួន ១០រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជួយអភិវឌ្ឍន៍ វិស័យកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ :**

| | | | | |
|---|---|---|---|---|
| - | លោក | **Youqiong** | **Wang** | តំណាងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម |

**ខ.មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ :**

| | | | | |
|---|---|---|---|---|
| ១- | លោក | **Philippe** | **Becu** | ជំនាញការអន្តរជាតិប្រចាំគម្រោង ECOSORN |
| ២- | លោកស្រី | **Diane** | **Caroen** | ជំនាញការអន្តរជាតិប្រចាំគម្រោង ECOSORN |
| ៣- | លោក | **Ab** | **Koster** | ជំនាញការអន្តរជាតិប្រចាំគម្រោង ECOSORN |
| ៤- | លោក | **Kim Byung** | **Gwan** | ជំនាញការប្រចាំសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ៥- | លោក | **Pierre** | **GRARD** | ជំនាញការប្រចាំសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ៦- | កញ្ញា | **SUSAN** | **Kauffman** | ជំនាញការប្រចាំសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ៧- | កញ្ញា | **Amy** | **Kauffman** | ជំនាញការប្រចាំសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ៨- | លោក | **Philippe** | **MONNIN** | ទីប្រឹក្សាបច្ចេកទេសអមអគ្គនាយកដ្ឋានកៅស៊ូ |
| ៩- | លោក | **Stephane** | **BOULAKIA** | ជំនាញការផ្នែកដំណាំពិពិធកម្មកសិកម្ម |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៩៣ . អនក្រ . បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន១៧រូប ដែលបានផ្តល់ថវិកា ជួយរៀបចំបណ្តាញអគ្គិសនីថ្មី នៅសារមន្ទីរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដោយចំណាយអស់ថវិកាសរុបចំនួន ១៧៧.៥០០ ដុល្លារ ដូចមានរាយនាមខាងក្រោម :-

**១-Mr. Marc Quinn**
**២-Mr. & Mrs. Eskenazi**
**៣-Mr. & Mrs. Yothin Tharahirunchot**
**៤-Mr. & Mrs. Rodolitz**
**៥-Ms. Nancy Wiener**
**៦-The Foundation for the Encouragement of Arts**
**៧-Mrs. Emma C. Bunker**
**៨-Mr. Carlton Rochell Jr.**
**៩-Mr. & Mrs. Kessler**
**១០-Mr. & Mrs. Perry-Smith**
**១១-Mr. Richard A. Dragisic**

១២-Ms. Ellen Hamilton

១៣-Mr. Sitthi Charoenrith

១៤-Mr. Charoenratana

១៥-Mr. Yai

១៦-Mr. Joey Shawcross

១៧-Mr. & Mrs. S. Copleston

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៩៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត ១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់គ្រឿងឥស្សរិយយស **សហមេត្រី** ជូនដល់គ្រូបង្រៀនវៀតណាមចំនួន ០៧ រូបនៃសាលាមធ្យមសន្តិសុខប្រជាជន ២ នៅភាគខាងត្បូង ប្រទេសវៀតណាមបានរួមសហការល្អក្នុងការជួយបណ្តុះបណ្តាលវគ្គបំប៉នជំនាញការពារ សន្តិសុខ និងថ្នាក់ដឹកនាំដល់មន្ត្រីនគរបាលជាតិកម្ពុជា។

**ក. គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១ | លោកវរសេនីយ៍ឯក | Tong Duy Thoai | នាយកសាលា |
| ២ | លោកវរសេនីយ៍ឯក | Nguyen The Hanh | នាយករងសាលា |
| ៣ | លោកវរសេនីយ៍ឯក | Phan Anh Chuyen | នាយករងសាលា |
| ៤ | លោកវរសេនីយ៍ឯក | Le Van Thien | នាយករងសាលា |

**ខ. គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់សេនា**

| | | | |
|---|---|---|---|
| ៥ | លោកវរសេនីយ៍ឯកប៉ុរ៉ុង | Nguyen Duy Quyet | នាយការិយាល័យ |
| ៦ | លោកវរសេនីយ៍ឯកប៉ុរ៉ុង | Nguyen Dang Lam | នាយរងការិយាល័យ |

**គ. គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់អស្សឫទ្ធិ**

| | | | |
|---|---|---|---|
| ៧ | លោកអនុសេនីយ៍ឯក | Nguyen Thi Tuyet Huong | នាយផ្នែក |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា១ និងមាត្រា២*
*-រាជកិច្ច ✓*
*-ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនអស់លោក លោកស្រី ជាទីប្រឹក្សាអន្តរជាតិ និងជាដៃគូអភិវឌ្ឍន៍ចំនួន ១៤ រូប ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចដំណើរការវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម :

**ក. មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនចំពោះ :

១-លោក JULIAN ABRAMS ទីប្រឹក្សា នៃលេខាធិការដ្ឋាន គ.ជ.អ.ប

**ខ. មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនចំពោះ :

១-លោក HANS VAN ZOGGEL ទីប្រឹក្សា នៃលេខាធិការដ្ឋាន គ.ជ.អ.ប

**គ. មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនចំពោះ :

| | | |
|---|---|---|
| ១-លោក | YOUQIONG WANG | ប្រធានក្រុមការងារគំរោង IFAD |
| ២-លោកស្រី | LOU SCURA | ប្រធានក្រុមការងារគំរោង RILG |
| ៣-លោក | ERIK ILLES | អ្នកសម្របសម្រួលនៃដៃគូអភិវឌ្ឍន៍ |
| ៤-លោកស្រី | REBEA BRAUER | ប្រធានទីប្រឹក្សាសហគមន៍អឺរ៉ុប EC |
| ៥-លោក | ANDREW WARDELL | ប្រធានទីប្រឹក្សាគំរោង NRM |

| | | |
|---|---|---|
| ៦-លោក | JEAN DE SPIEGELEER | ទីប្រឹក្សា និងជាស្ថាបត្យករ |
| ៧-លោក | TOM WINGFIELD | ប្រធានទីប្រឹក្សា DfID |
| ៨-លោកស្រី | KATARINA HUEBNER | ប្រធានទីប្រឹក្សា GTZ |
| ៩-លោកស្រី | JACINTA BARRINS | ទីប្រឹក្សា UNDP |
| ១០-លោក | STEVENS TUCKER | ប្រធានទីប្រឹក្សា PACT |
| ១១-លោកស្រី | JULIA REES | ប្រធានទីប្រឹក្សា UNICEF |
| ១២-លោក | KASHIYASU KATO | ប្រធានទីប្រឹក្សាគំរោង PILAC |

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៣៥ សសរ**

# សេចក្តីសម្រេច
## ស្តីពី
## ការបន្ថែមសមាសភាពគណៈកម្មការជំរុញការនាំចេញកសិផល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចលេខ ២១ សសរ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មការ ជំរុញការនាំចេញកសិផល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**ប្រការ ១ៈ** ត្រូវបានបន្ថែមសមាសភាពគណៈកម្មការជំរុញការនាំចេញកសិផល ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តមបណ្ឌិត **ប៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ២- | លោក **ហាប់ ចាន់ធា** | អនុប្រធាននាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ ២ៈ** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ ឧសភា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៣៦ សសរ**

# សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួស**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍ ២០ ឆ្នាំ នៃទំនាក់ទំនងអាស៊ាន-សាធារណរដ្ឋកូរ៉េ និងបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋកូរ៉េ ចាប់ពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៩ រហូតដល់សម្តេចតេជោនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលរាជធានី ខេត្ត-ក្រុង និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចំលងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ**......០៤......សណណន

**សារាចរណែនាំ**

**ស្តីពី**

**ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១០**

## I. សេចក្តីផ្តើម

១- មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានបែងចែកកិច្ចដំណើរការនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ជា ៣ ដំណាក់កាលគឺ (១) *ដំណាក់កាលទី១:* ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាពីខែមីនា ដល់ខែឧសភា (២) *ដំណាក់កាលទី ២:* ការរៀបចំកញ្ចប់ថវិកា ពីខែមិថុនា ដល់ខែកញ្ញា និង*ដំណាក់កាលទី ៣:* ការអនុម័តថវិកាពីខែ តុលា ដល់ខែធ្នូ ។ ដើម្បីធានាការអនុវត្តច្បាប់នេះ និងដើម្បីបង្កើនការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ រាជរដ្ឋាភិបាលត្រូវចេញសារាចរណែនាំពីរគឺ ***សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា*** នៅដើមខែមេសា សម្រាប់ដំណាក់កាលទី ១ និង ***សារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំ*** នៅដើមខែមិថុនា សម្រាប់ដំណាក់កាលទី ២ ។ ដូច្នេះ សារាចរនេះគឺជាមគ្គុទ្ទេសក៍ សម្រាប់ណែនាំ និងធ្វើជាជំនួយដល់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០១០-២០១២ ដល់គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញគ្រប់រាជធានី ខេត្តទាំងអស់ ។

២- ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា ជាពិសេស ដើម្បីបង្កើនការវិភាជន៍ថវិកាអោយចំទិសដៅ និងបំរើអោយសកម្មភាពអាទិភាពជាក់ស្តែងរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ក្នុងគោលដៅសំរេចអោយបាន នូវគោលនយោបាយយុទ្ធសាស្ត្ររបស់ក្រសួង-ស្ថាប័ននីមួយៗ ក៏ដូចជាគោលនយោបាយយុទ្ធសាស្ត្រជាអាទិភាពរបស់វិស័យនីមួយៗ សំរាប់រួមចំណែក សំរេចអោយបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ជាពិសេស **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** តម្រូវអោយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្តនីមួយៗ រៀបចំ និង ធ្វើបច្ចុប្បន្នភាព ***ផែនការយុទ្ធសាស្ត្រថវិកា*** ជារៀងរាល់ឆ្នាំ ។ ផែនការយុទ្ធសាស្ត្រថវិកានេះ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ (១) ផ្សារភ្ជាប់គោលនយោបាយទៅនឹងថវិកា (២) បង្កើនសុក្រឹតភាពក្នុងការគណនាតម្រូវការថវិកា (៣)ជាមូលដ្ឋានសម្រាប់ពន្យល់ និងធ្វើអំណះអំណាងលើតម្រូវការថវិកា (៤) ធានានិរន្តរភាពនៃកម្មវិធី

និងយុទ្ធសាស្ត្រ អាទិភាព និងពិសេស (៥) គឺជាមូលដ្ឋានសម្រាប់វាយតំលៃលើអាទិភាពក្នុងការកំណត់កញ្ចប់ និង វិភាជន៍ថវិកា ។

៣- ផែនការយុទ្ធសាស្ត្រថវិកានេះ បាន និងកំពុងក្លាយជាឧបករណ៍ និងយន្តការដ៏សំខាន់សម្រាប់បង្កើនប្រសិទ្ធភាពនៃការវិភាជន៍ និងការគ្រប់គ្រងថវិកា ជាពិសេស សម្រាប់ធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ទាំងថវិកាជាតិ និងថវិកាផ្ដល់ដោយដៃគូអភិវឌ្ឍន៍ ឱ្យទៅជាថវិកាមួយឯកភាព និងគ្រប់ជ្រុងជ្រោយ ។ ដើម្បីអោយការរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះ អាចប្រព្រឹត្តទៅដោយរលូន និងគ្រប់ជ្រុងជ្រោយ ជាពិសេស ដោយផែនការយុទ្ធសាស្ត្រថវិកានេះ តម្រូវអោយផ្សារភ្ជាប់ទៅនឹងគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធន ព្រមទាំងថវិកាជាតិ និងថវិកាដែលផ្ដល់ដោយដៃគូអភិវឌ្ឍន៍ផងនោះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវប្រើប្រាស់ក្រុមការងារថវិការបស់ក្រសួង-ស្ថាប័ន ដែលមានសមាសភាពមកពីនាយកដ្ឋានហិរញ្ញវត្ថុ ឬ/និងគណនេយ្យ នាយកដ្ឋានផែនការ និងអង្គភាពគ្រប់គ្រងគំរោង ។ ក្រុមការងារនេះ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើគោលនយោបាយអាទិភាពរបស់ក្រសួង-ស្ថាប័ន និងវិស័យ ដើម្បីដាក់ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពិនិត្យសំរេច និង ចុះហត្ថលេខា ។ គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាដែលបានរៀបចំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) អោយបាន ***ត្រឹមថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩*** ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និង អាចអញ្ជើញតំណាងក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត មកពិគ្រោះ និងសាកសួរព័ត៌មានបន្ថែមក្នុងករណីចាំបាច់ ។ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ដែលមិនបានផ្ដល់ផែនការយុទ្ធសាស្ត្រថវិកាតាមពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិវិភាជន៍កញ្ចប់ថវិកាដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ ។

## II. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

### *ក. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច*

៤- សេដ្ឋកិច្ចកម្ពុជាកំពុងតែបន្តវិវត្តផ្លាស់ប្ដូររចនាសម្ព័ន្ធ ដើម្បីឈានទៅរកដំណាក់កាលនៃការអភិវឌ្ឍន៍មួយខ្ពស់ជាងមុន ដែលឆ្លុះបញ្ចាំងតាមរយៈ ការកើនឡើងជាលំដាប់នៃសមាមាត្រវិស័យឧស្សាហកម្ម និងសេវាកម្ម ធៀបនឹងកសិកម្ម នៅក្នុងរចនាសម្ព័ន្ធនៃផលិតផលក្នុងស្រុកសរុប (ផសស) ។ ជាក់ស្ដែង ទោះជាផលិតភាពនៃវិស័យកសិកម្មបាន និង បន្តកើនឡើង តែកំណើននៃវិស័យឧស្សាហកម្ម និងសេវាកម្ម បានកើនឡើងលឿនជាងពីមួយឆ្នាំទៅមួយឆ្នាំ ដែលធ្វើអោយការរួមចំណែកនៃវិស័យកសិកម្មថយចុះនៅឆ្នាំ ២០០៨ មកនៅត្រឹមប្រមាណ ៣៣% ហើយវិស័យឧស្សាហកម្មឡើងដល់ប្រមាណ ២៨% និងវិស័យសេវាកម្មឡើងដល់ ៤០% ។ ទោះជាយ៉ាងណាក៏ដោយ វិស័យកសិកម្មនៅតែជាមូលដ្ឋានសំខាន់ និងមានសក្ដានុពលខ្ពស់ក្នុងការជំរុញ និង ពង្រីកកំណើនសេដ្ឋកិច្ចកម្ពុជា ជាពិសេស នៅក្នុងបរិការណ៍ដែលវិស័យឧស្សាហកម្ម និងសេវាកម្ម បាន និង កំពុងរងឥទ្ធិពលនៃវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងនៃនិនភាព

សេដ្ឋកិច្ចពិភពលោក ។ ប្រការនេះ កាន់តែបញ្ជាក់អោយឃើញថា ការបង្កើនទិន្នផល និងផលិតភាពកសិកម្ម ការធ្វើពិពិធកម្មរូបនីយកម្មមូលដ្ឋាននៃកំណើនវិស័យកសិកម្ម និង ការជំរុញការអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម ព្រមទាំងសហគ្រាសធុនតូច និង មធ្យម រួមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ នៅតែជាយុទ្ធសាស្រ្តដ៏សំខាន់ និងចាំបាច់ ដើម្បីបង្កើនតម្លៃបន្ថែមលើផលិតផលកសិកម្ម និង ស្រូបយកពលកម្ម ដែលចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេស ពលកម្មដែលត្រូវផ្ទេរចេញពីវិស័យកសិកម្ម និងដើម្បីពង្រីកមូលដ្ឋានកំណើន រក្សាចីរភាព និងសមធម៌នៃកំណើនសេដ្ឋកិច្ច ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ របស់ប្រជាជន ស្របតាមគោលនយោបាយ **យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២** ក៏ដូចជា **ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ** ។

**៥-** ឆ្នាំ ២០០៨ កន្លងទៅនេះ តាមការគណនាបឋមរបស់វិទ្យាស្ថានជាតិស្ថិតិ កំណើនសេដ្ឋកិច្ចអាចនឹងសម្រេចបានប្រមាណ ៦,៨% ទោះជាត្រូវរងនូវឥទ្ធិពលអវិជ្ជមានពីខាងក្រៅតាំងពីចុងឆ្នាំ ២០០៧ រហូតមកដូចជាកត្តាអតិផរណាខ្ពស់ ការចាប់ធ្លាក់ចុះនូវការនាំចេញសំលៀកបំពាក់ និងចំនួនភ្ញៀវទេសចរ ព្រមទាំងការធ្លាក់ចុះនៃទីផ្សារអចលនទ្រព្យ ដោយសារវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងឱនភាពសេដ្ឋកិច្ចពិភពលោក ដែលចាប់ផ្តើមពីសហរដ្ឋអាមេរិកក៏ដោយ ។ លទ្ធផលនេះ បានមកដោយសារវិស័យកសិកម្មបានកើនឡើងប្រមាណ ៥,៤% លើកំណើន ៥% នៅក្នុងឆ្នាំ ២០០៧ វិស័យឧស្សាហកម្មបានកើនឡើងប្រមាណ ៦,៥% លើកំណើន ៨,៤% នៅក្នុងឆ្នាំ ២០០៧ (ដែលក្នុងនោះ ផលិតផលវាយនភ័ណ្ឌបានកើនឡើងត្រឹមប្រមាណ ៦,៥% លើកំនើន ១០% នៅក្នុងឆ្នាំ ២០០៧ ហើយផលិតផលសំណង់បានកើនឡើងត្រឹមប្រមាណ ៦,៥% លើកំនើន ៦,៧% នៅក្នុងឆ្នាំ ២០០៧) ហើយវិស័យសេវាកម្មបានកើនឡើងប្រមាណ ៨% លើកំណើន ១០% នៅក្នុងឆ្នាំ ២០០៧ (ដែលក្នុងនោះ អាជីវកម្មទេសចរណ៍ បានកើនឡើងប្រមាណ ៨% លើកំណើន ១០% នៅក្នុងឆ្នាំ ២០០៧) ។

**៦-** តាមការព្យាករណ៍ដោយមានលក្ខណៈប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០០៩ នេះ អាចនឹងសម្រេចបានត្រឹមប្រមាណពី ១% ទៅ ២% ធៀបទៅនឹងការព្យាករណ៍ ៦,៥% នៅក្នុងការរៀបចំច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។ ទោះជាត្រូវទទួលឥទ្ធិពលពីខាងក្រៅ ដូចជាការធ្លាក់ចុះនៃសេដ្ឋកិច្ចអាមេរិក និងការប្រឈមនឹងការប្រកួតប្រជែងលើទីផ្សារវាយនភ័ណ្ឌ ពីប្រទេសវៀតណាម និងចិនក៏ដោយ ក៏កំណើននៃតម្រូវការក្នុងស្រុក និងលំហូរចូលនៃមូលធនពីក្រៅប្រទេសនឹងនៅតែបន្តកើនឡើងគ្រប់គ្រាន់សម្រាប់រក្សាកំណើនមិនអោយធ្លាក់ចុះក្រោមសូន្យដែរ ។ ជាពិសេស វិស័យកសិកម្មនឹងនៅតែកើនឡើងប្រមាណ ៤,៥% វិស័យឧស្សាហកម្មនឹងធ្លាក់ចុះប្រមាណពី ២% ទៅ ៣% ពិសេសដោយសារការធ្លាក់ចុះនៃផលិតផលវាយនភ័ណ្ឌ និងផលិតផលសំណង់ដែលអាចធ្លាក់ដល់ប្រមាណពី ៥% ទៅ ១០% និងវិស័យសេវាកម្មនឹងអាចកើនឡើងត្រឹមប្រមាណ ១% ដោយសារអាជីវកម្មទេសចរណ៍អាចនឹងធ្លាក់ចុះប្រមាណ ៥% ។

៧- អតិផរណានៅចុងឆ្នាំ ២០០៨ បានកើនឡើងរហូតដល់ ១២,៥% (តាមឆ្នាំគោល ២០០៦) ដោយសារកត្តាឥទ្ធិពលពីខាងក្រៅនិងកត្តាកំណើនតម្រូវការក្នុងស្រុក ក៏បានរួមចំណែកក្នុងការធ្វើអោយថ្លៃទំនិញមួយចំនួនឡើងថ្លៃដែរ ជាពិសេស ម្ហូបអាហារ និងសំភារៈប្រើប្រាស់ ដោយសារចំណូលរបស់ប្រជាជនបានកើនឡើង និងកំណើនទេសចរណ៍ ។ តាមការព្យាករណ៍ អតិផរណា ជាមធ្យមនៅក្នុងឆ្នាំ ២០០៩ នឹងធ្លាក់មកនៅត្រឹមរង្វង់ប្រមាណ ៤% (តាមឆ្នាំគោល២០០៦) និងនៅឆ្នាំ ២០១០ ខាងមុខអាចនឹងស្ថិតនៅក្នុងរង្វង់ប្រមាណ ៥% ដោយសារសេដ្ឋកិច្ចពិភពលោកបានក្រឡាប់ចាក់ ១៨០ អង្សារ គឺពីអតិផរណាខ្ពស់ ថ្លៃប្រេងឥន្ធនៈខ្ពស់ និងថ្លៃស្បៀងអាហារខ្ពស់ នៅពាក់កណ្តាលឆ្នាំ ២០០៨ មករកបដិផរណា គឺការធ្លាក់ចុះនៃថ្លៃស្បៀងអាហារ និងថ្លៃប្រេងឥន្ធនៈ និងដោយសារកត្តាក្នុងស្រុកដែលរងឥទ្ធិពលពីវិបត្តិទីផ្សារហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោក ដូចជា ការធ្លាក់ចុះនូវចំណូលរបស់ប្រជាជន និងចំនួនភ្ញៀវទេសចរ ព្រមទាំងការធ្លាក់ចុះនៃទីផ្សារអចលនទ្រព្យ ។

៨- ជារួមតាមការវាយតម្លៃ និងព្យាករណ៍របស់សហគមន៍អន្តរជាតិ ទោះជាឆ្នាំ ២០០៩ នេះ សេដ្ឋកិច្ចពិភពលោកពោរពេញដោយភាពទុទ្ទិដ្ឋិនិយមយ៉ាងណាក៏ដោយ ក៏ប្រទេសភាគច្រើនសង្ឃឹមថា សេដ្ឋកិច្ចពិភពលោកនឹងងើបឡើងវិញនៅក្នុងឆ្នាំ ២០១០ ខាងមុខនេះ ជាពិសេស បណ្តាប្រទេសនៅអាស៊ី ។ ការវាយតម្លៃ និងសេចក្តីសង្ឃឹមនេះ គឺដោយផ្អែកលើកិច្ចសហការរវាងបណ្តាប្រទេសនៅគ្រប់តំបន់ ដើម្បីជំរុញគោលនយោបាយពង្រីកចំណាយលើវិស័យសាធារណៈ ពិសេសវិស័យមានផលិតភាពខ្ពស់ និងហេដ្ឋារចនាសម្ព័ន្ធដែលជំរុញកំណើនសេដ្ឋកិច្ច និងចំណាយលើការការពារសុវត្ថិភាពសង្គម ព្រមទាំងការជួយស្រោចស្រង់វិស័យឯកជន ។ ដោយឈរលើមូលដ្ឋានខាងលើនេះ កំណើនសេដ្ឋកិច្ចត្រូវបានព្យាករណ៍សំរាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១០ គឺស្ថិតក្នុងរង្វង់ ៣% ។ ទោះជាយ៉ាងណាក៏ដោយ ស្ថិតក្នុងបរិការណ៍ប្រកបដោយភាពមិនច្បាស់លាស់ខ្ពស់បែបនេះ រាជរដ្ឋាភិបាល នឹងបន្តពង្រឹងការតាមដាន និង គ្រប់គ្រងសភាពការណ៍យ៉ាងម៉ត់ចត់ និងជាប្រចាំ ព្រមទាំងបន្តជំរុញការអនុវត្ត ប្រកបដោយភាពទន់ភ្លន់ និងដាក់ចេញនូវវិធានការថ្មីៗ ទៀតទៅតាមការវិវត្តនៃស្ថានភាពជាក់ស្តែង ។ រាជរដ្ឋាភិបាលនៅតែប្រកាន់មហិច្ឆិតាខ្ពស់ក្នុងការសំរេចឱ្យបាននូវគោលដៅកំណើនសេដ្ឋកិច្ចប្រមាណ ៧% និងកាត់បន្ថយភាពក្រីក្រឱ្យបានជាង ១% ក្នុងមួយឆ្នាំៗ ស្របតាមគោលដៅនយោបាយនៃ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** ។

### ***ខ. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ***

៩- ទោះជាឆ្នាំ ២០០៩ នេះ កំណើនសេដ្ឋកិច្ចអាចនឹងសម្រេចបាន (១-២%) ទាបជាងគោលដៅ ៦,៥% ពេលរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ក៏ដោយ ក៏យើងសង្ឃឹមថានឹងមិនមានឥទ្ធិពលធ្ងន់ធ្ងរមកលើស្ថានភាពហិរញ្ញវត្ថុសាធារណៈដែរ ពិសេស លើការអនុវត្តថវិកា ។ ការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពត្រឹមត្រូវ និងប្រុងប្រយ័ត្នខ្ពស់ គួបផ្សំជាមួយនឹងការជំរុញការកែលម្អ និងការពង្រឹងការប្រមូល និងគ្រប់គ្រងចំណូល និងការកែលម្អ និងពង្រឹងការអនុវត្ត និង ការគ្រប់គ្រងចំណាយ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំង

ការផ្តើអាទិភាពចំណាយឡើងវិញសមស្រប នោះនឹងអាចធ្វើអោយការអនុវត្តថវិកាឆ្នាំ ២០០៩ សម្រេចបាន តាមគោលដៅនៃច្បាប់ហិរញ្ញវត្ថុ ។ តាមការព្យាករណ៍ចំណូល សរុបនឹងអាចកើនឡើងប្រមាណ ០,២% ធៀបនឹងការអនុវត្តក្នុងឆ្នាំ ២០០៨ គឺចំណូលក្នុងស្រុកសរុបនឹងសម្រេចបាន ១១,៩៨% នៃផសស ដែលក្នុងនោះ ចំណូលសារពើពន្ធនឹងសម្រេចបាន ១០,០៥% នៃផសស (ក្នុងនោះ ចំណូលគយ និងរដ្ឋាករស្មើនឹង ៥,៣០% និងចំណូលពន្ធដារស្មើនឹង ៣,៧៥%) ចំណូលមិនមែនសារពើពន្ធ នឹងសម្រេចបាន ១,៨៣% នៃផសស ។ ចំណាយសរុបអាចនឹងកើនដល់ ១៧,៧៨% នៃផសស គឺកើនឡើងប្រមាណ ៣៤,៥% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ដែលក្នុងនោះ ចំណាយចរន្តនឹងកើនដល់ប្រមាណ ១០,៦៩% នៃផសស គឺកើនឡើង ៤៤,២% ធៀបនឹងឆ្នាំ ២០០៨ និងចំណាយមូលធនអាចនឹងកើនដល់ប្រមាណ ៧,០៩% នៃផសស គឺកើនឡើងប្រមាណ ២២,១% ធៀបនឹងការអនុវត្តក្នុងឆ្នាំ២០០៨ ។ ការអនុវត្តចំណូល និងចំណាយនេះ អាចនឹងធ្វើអោយមានអតិរេក ចរន្តប្រមាណ ១,២% នៃផសស និងឱនភាពថវិកាសរុបប្រមាណ ៥,៨% នៃផសស ។

១០- ដោយឈរលើមូលដ្ឋាននៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** របស់រាជរដ្ឋាភិបាល គួបផ្សំនឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ថវិកាឆ្នាំ ២០១០ មានគោលដៅសំខាន់ៗដូចតទៅ :

- ការជំរុញការអនុវត្ត **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** ***ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព*** និងធានាការបន្តអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** សំដៅសម្រេច គោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។
- ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល ៣ ឆ្នាំ ២០១០-២០១២ ។
- ធានាការអនុវត្តគោលនយោបាយអាទិភាពតាមវិស័យ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ដូចជា:
  - ការបន្តផ្តល់អាទិភាពដល់ការបង្កើន និងលើកកំពស់សេវាសាធារណៈនៅក្នុងវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំ និងសុខាភិបាល
  - ការបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់សកម្មភាពដែលបំរើអោយវិស័យ សេដ្ឋកិច្ច ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍន៍ជនបទ ។
- ធានាការបន្តអនុវត្តកម្មវិធីកែទម្រង់ និង អភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ កម្មវិធីកែទម្រង់ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ កម្មវិធីកែទម្រង់កងទ័ព កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ កម្មវិធីអភិវឌ្ឍន៍ផ្នែកឯកជន និងការពង្រឹងអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាល ។

១១- ដើម្បីធានាអោយបាននូវការអនុវត្តទៅតាមគោលដៅខាងលើនេះ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដែលបានគូសបញ្ជាក់ខាងលើ ថវិកាឆ្នាំ ២០១០ ត្រូវគ្រោងនិងរៀបចំឡើងលើមូលដ្ឋានយុទ្ធសាស្ត្រ និងវិធានការដូចខាងក្រោម ÷

- បន្តពង្រឹងការគ្រប់គ្រងចំណូល និងជំរុញការប្រមូលចំណូល ជាពិសេស ការអនុវត្តអោយបានសម្រេចទៅតាមផែនការសកម្មភាព និង គោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសម្រេចអោយបាននូវកម្រិតចំណូលក្នុងស្រុកសរុបប្រមាណ ១២,៦% នៃផសស គឺមានកំណើន ០,៦% នៃផសស ធៀបនឹងឆ្នាំ ២០០៩ ដែលក្នុងនោះ ចំណូលសារពើពន្ធត្រូវសម្រេចអោយបាន ១០,៦% នៃផសស គឺមានកំណើន ០,៥% នៃផសស ធៀបនឹងឆ្នាំ ២០០៩ ចំណូលមិនមែនសារពើពន្ធត្រូវសម្រេចអោយបាន ១,៩% នៃផសស ប្រហាក់ប្រហែលនឹងឆ្នាំ ២០០៩ ។

- បន្តពង្រឹងការរៀបចំថវិកា អោយកាន់តែមានភាពច្បាស់លាស់ និងសុក្រឹតភាព តាមរយៈ ការបន្តជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំគោលនយោបាយចំណូល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមអោយបានច្បាស់លាស់ និងសុក្រឹត ការធ្វើសមាហរណកម្មថវិកា និងការបន្តកែលម្អការអនុវត្តថវិកាតាមកម្មវិធី ។

- បន្តពង្រឹងការគ្រប់គ្រងចំណាយ ជាពិសេស បន្តពង្រឹង និងជំរុញការកែលម្អការអនុវត្ត ថវិកាតាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងពាក់កណ្តាលឆ្នាំ ការបន្តពង្រឹងការអនុវត្តវិសហមជ្ឈការលទ្ធកម្មសាធារណៈ និងការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុងដើម្បីបន្តពង្រឹង ***ភាពជឿទុកចិត្តបាននៃថវិកា*** ដែលសម្រេចបាននៅក្នុង ដំណាក់កាលទី ១ ដែលនឹងនៅតែជាមូលដ្ឋានដ៏សំខាន់ និងចាំបាច់សម្រាប់ការឈានទៅដំណាក់កាលទី២ ***គឺការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ*** និង បណ្តាដំណាក់កាលបន្តបន្ទាប់ទៀត ។

- បន្តពង្រឹង និងបង្កើនការអនុវត្តប្លង់គណនេយ្យថ្មី និងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាថ្មី ប្រព័ន្ធកត់ត្រា និងរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុ អោយកាន់តែសុក្រឹត ព្រមទាំង ការត្រួតពិនិត្យផ្ទៃក្នុង និង ជាពិសេស ឈានទៅកំណត់ និងដាក់អោយអនុវត្តនូវចំណាត់ថ្នាក់មុខងារ អង្គភាពថវិកា បរិបថ និងនីតិវិធីអនុវត្តថវិកាថ្មី ដើម្បីឈានទៅអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យា ដែលជាសកម្មភាពការងារដ៏ចំបងសម្រាប់សម្រេចជំហានទី ២ គឺ ***ការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ*** នៅក្នុងក្របខ័ណ្ឌនៃកម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

- បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តសន្សំសំចៃលើមុខសញ្ញាចំណាយ អគ្គិសនី ទូរស័ព្ទ ប្រេងឥន្ធនៈ ដើម្បីរក្សាចំណាយសរុបអោយស្ថិតនៅក្នុងកម្រិត ១៧,៧% នៃផសស គឺកើនឡើងប្រមាណ ០,១% នៃផសស ធៀបនឹងឆ្នាំ ២០០៩ ដែលក្នុងនោះ ចំណាយចរន្តនឹងត្រូវបានរក្សាអោយនៅត្រឹមប្រមាណ ១០,៦% និងចំណាយមូលធននឹងត្រូវបានរក្សានៅត្រឹមប្រមាណ ៧,១% នៃផសស ក្នុងទិសដៅរក្សាអតិរេកចរន្តក្នុងរង្វង់ ១,៩% នៃផសស និងឱនភាពថវិកាសរុប ក្នុងរង្វង់ ៥% នៃផសស ដោយមិនគិតហិរញ្ញប្បទានឥតសំណង និងប្រមាណ ៣% នៃផសស ដោយគិតទាំងហិរញ្ញប្បទានឥតសំណង ។

• បន្តផ្តល់អាទិភាព និងជំរុញការអនុវត្តថវិកាតាមកម្មវិធី និងការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដើម្បីបង្កើនប្រសិទ្ធភាពថវិកា និង ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ជាពិសេស បន្តពិនិត្យលទ្ធភាពដើម្បីពង្រីកការសាកល្បងការអនុវត្ត ថវិកាតាមកម្មវិធីតាមរយៈការបង្កើនទំហំថវិកាតាមកម្មវិធី និង ពង្រីកការអនុវត្តទៅក្រសួងផ្សេងទៀតក្រៅពីក្រសួង ៨ ដែលបាន និងកំពុងអនុវត្តនៅក្នុងឆ្នាំ ២០០៩ នេះ (ក្រសួងអប់រំយុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងយុត្តិធម៌ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកិច្ចការនារី និងក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ) ។

• បន្តផ្តល់អាទិភាពលើកិច្ចការវិនិយោគសាធារណៈ ជាពិសេស លើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានផ្លូវ ស្ពាន ប្រព័ន្ធស្រោចស្រព និងការវិនិយោគលើការលើកកម្ពស់ផលិតភាពកសិកម្ម និង កសិ-ឧស្សាហកម្ម ។

## III. សេចក្តីណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

១២- ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០០៩-២០១១ របស់ខ្លួន និង ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈខាងលើ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត នីមួយៗ ត្រូវត្រួតពិនិត្យឡើងវិញ និងវាយតំលៃលើការអនុវត្តកន្លងមក ដើម្បីកែសម្រួល និងរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១០-២០១២ ទៅតាមគំរូដូចបានភ្ជាប់មកជាមួយសារាចរណែនាំនេះ ។ គំរូផែនការយុទ្ធសាស្ត្រថវិកា ២០១០-២០១២ ដែលត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នេះរួមមាន ៥ ផ្នែកគឺៈ

***ផ្នែកទី ១: មុខងារ និងភារកិច្ច*** គឺជាការបញ្ជាក់អំពីមុខងារ ភារកិច្ច និង ការទទួលខុសត្រូវរួមរបស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្ត ដែលបានកំណត់ និងប្រគល់ដោយរាជរដ្ឋាភិបាល ។

***ផ្នែកទី ២: ទិសដៅគោលនយោបាយ*** គឺជាទិសដៅគោលនយោបាយរយៈពេលមធ្យម (ពី ៣ ទៅ ៥ ឆ្នាំ) ដែលត្រូវបានកំណត់ដោយក្រសួង-ស្ថាប័ន ដើម្បីអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ដែលរាជរដ្ឋាភិបាលបានប្រគល់ជូន ជាពិសេស ដើម្បីរួមចំណែកអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** ដើម្បី កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ជីវភាពរបស់ប្រជាពលរដ្ឋ ។

***ផ្នែកទី ៣: កម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាព និង តំរូវការធនធាន*** គឺជាកម្មវិធី ឬយុទ្ធសាស្ត្រ អាទិភាពដែលកំណត់ដោយក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ដើម្បីអនុវត្ត និងសំរេច អោយបាននូវទិសដៅគោលនយោបាយរយៈពេលមធ្យមដែលបានកំណត់នៅក្នុងផ្នែកទី ២ ខាងលើ ។ ការកំណត់កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនេះ ត្រូវតែមានលក្ខណៈគ្រប់ជ្រុងជ្រោយ គឺរួមមានទាំង កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពសម្រាប់ថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ ។ កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ត្រូវគណនាតំរូវការធនធានអោយបានច្បាស់លាស់ទៅតាមឆ្នាំ ប្រភេទចំណាយ និងប្រភពធនធាន ដូចក្នុងតារាងទី ៣.១ និង៣.២ នៃគំរូផែនការយុទ្ធសាស្ត្រ ថវិកាដែលភ្ជាប់ជាមួយសារាចរណែនាំនេះ ។

***ផ្នែកទី ៤: ការកំណត់សូចនាករ និងគោលដៅសូចនាករ*** គឺជាការកំណត់សូចនាករ និងគោលដៅសម្រាប់វាស់លទ្ធផលសម្រេចបានពីការអនុវត្តកម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាពនីមួយៗ ដែលក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត បានកំណត់ ដើម្បីសំរេចបាននូវគោលដៅនៃ ទិសដៅគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ដែលនឹងរួមចំណែកក្នុងការអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** របស់រាជរដ្ឋាភិបាល ។ សូចនាករនីមួយៗ ត្រូវមានការពន្យល់ពីមូលហេតុដែលត្រូវបានជ្រើសរើស បញ្ជាក់អំពីស្ថានភាពបច្ចុប្បន្ន កំណត់គោលដៅនៃលទ្ធផលក្នុងឆ្នាំនីមួយៗ និងកំណត់គោលដៅនៃលទ្ធផលចុងក្រោយ ដូចក្នុងតារាងទី ៤.១ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មកជាមួយសារាចរណែនាំនេះ ។

***ផ្នែកទី ៥: ការគ្រោង និង ព្យាករណ៍ចំណូល*** គឺជាការគ្រោង និងព្យាករណ៍ចំណូលសម្រាប់ រយៈពេល ៣ ឆ្នាំ (២០១០-២០១២) របស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ដែលមាន ភារកិច្ចប្រមូលចំណូល ដោយផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ខាងលើ ព្រមទាំងលទ្ធផល និងបទពិសោធន៍ក្នុងការអនុវត្តនៃបណ្តាឆ្នាំកន្លងមក រួមទាំងគោលនយោបាយ និងវិធានការថ្មី ដែលគ្រោងនឹងដាក់អោយអនុវត្ត ។ ការគ្រោង និងព្យាករណ៍ចំណូលនេះ ត្រូវគិតបញ្ចូលគ្រប់ប្រភេទនៃចំណូលទាំងអស់ រួមទាំងចំណូលដែលបានមកពីដៃគូអភិវឌ្ឍន៍សម្រាប់ អនុវត្តគំរោងនៅក្នុងក្រសួង-ស្ថាប័ន ផងដែរ ។

១៣- ទទួលបានសារាចរណែនាំនេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ទាំងអស់ ត្រូវអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ ។ ក្នុងករណី ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញ រាជធានី ខេត្ត មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាអោយបានទាន់ពេលវេលាតាមកាលកំណត់ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០០៩*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

"***ដើម្បីជូនជ្រាប***"

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-រាជកិច្ច "ដើម្បីចុះផ្សាយ"

-គ្រប់ក្រសួង-ស្ថាប័ន

-គ្រប់អភិបាលរាជធានី-ខេត្ត

-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត

"***ដើម្បីអនុវត្ត***"

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ០៥ សរណន

# សារាចរណែនាំ
## ស្តីពី
## ការចាត់តាំងខួបអនុស្សាវរីយ៍លើកទី ១២៣ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩

ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែ ឧសភា គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃចលនាកម្មករអន្តរជាតិ។ នៅក្នុងប្រទេសកម្ពុជា ទិវាពលកម្មអន្តរជាតិថ្ងៃទី ០១ ខែ ឧសភា ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ ហើយបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានកំណត់យកថ្ងៃទី ០១ ខែ ឧសភា ជាថ្ងៃបុណ្យការងាររបស់ពលករកម្ពុជា និងជាថ្ងៃឈប់សម្រាករបស់មន្ត្រីរាជការ និងកម្មករនិយោជិតទាំងអស់ ដូចថ្ងៃបុណ្យជាតិ បុណ្យប្រពៃណី និងបុណ្យអន្តរជាតិនានាដែរ។ ឆ្នាំ ២០០៩ នេះ ជាខួបលើកទី ១២៣ នៃទិវាពលកម្មអន្តរជាតិ ដែលត្រូវប្រារព្ធស្របគ្នាជាមួយខួបលើកទី ៩០ នៃការបង្កើតអង្គការអន្តរជាតិខាងការងារ (ILO) ផងដែរ។

ស្ថិតក្នុងស្ថានភាពដែលវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោកកើតឡើងជាទូទៅ ហើយមានផលប៉ះពាល់ដល់ប្រទេសយើងផងដែរនោះ ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៩ នេះ ជាព្រឹត្តិការណ៍មួយ ដែលយើងត្រូវនាំគ្នាឧទ្ទិសចំពោះគោលបំណងរួមរបស់យើង គឺ ***" ខិតខំបង្កើនផលិតភាពការងារ គុណភាពផលិតផល ដើម្បីជំនះការលំបាកនានារបស់ប្រទេសជាតិ "*** ។

អាស្រ័យហេតុនេះ ដើម្បីរៀបចំប្រារព្ធខួបអនុស្សាវរីយ៍លើកទី ១២៣ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៩ នេះ ឱ្យប្រព្រឹត្តទៅបានល្អ រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំដូចខាងក្រោមនេះ :

១-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើជាស្ថាប័នស្នូលក្នុងការរៀបចំទិវាអន្តរជាតិនេះ ដោយចេញសេចក្តីជូនដំណឹងដល់មន្ទីររាជធានី ខេត្តក្រោមឱវាទ អង្គការវិជ្ជាជីវៈរបស់និយោជក អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត ម្ចាស់ និងនាយកក្រុមហ៊ុន ព្រមទាំងកម្មករ និយោជិត ដើម្បីណែនាំអំពីការឈប់សម្រាក និងបំផុសការជួបជុំសំណេះសំណាលស្វែងយល់ពីស្ថានភាពវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោក ឬ កំសាន្តសប្បាយតាមលទ្ធភាពរៀងៗខ្លួនរបស់សហគ្រាស គ្រឹះស្ថាន សំដៅបង្កបរិយាកាសយោគយល់គ្នារវាងកម្មករ និយោជិត និងនិយោជក។

ខិតខំបញ្ចៀសការប្រើប្រាស់រូបភាពទិវាពលកម្មអន្តរជាតិ ដើម្បីធ្វើសកម្មភាពទាំងឡាយណាដែលបណ្តាលឱ្យមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈរបស់សង្គម ។

ថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវជ្រើសរើសសហគ្រាស គ្រឹះស្ថាន ជានិមិត្តរូប ដើម្បីធ្វើការសំណេះសំណាលជាមួយកម្មករនិយោជិត ។

២-ក្រសួងព័ត៌មាន ត្រូវណែនាំប្រព័ន្ធឃោសនារបស់រដ្ឋ និងឯកជន ទទួលផ្សព្វផ្សាយសារលិខិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី ១២៣ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៩ ឱ្យបានទូលំទូលាយ ។

៣-ក្រសួងមហាផ្ទៃ អគ្គស្នងការនគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អាជ្ញាធររាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវមានវិធានការតាមសមត្ថកិច្ចរបស់ខ្លួនក្នុងការថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ក្នុងឱកាសទិវាពលកម្មអន្តរជាតិឆ្នាំ ២០០៩ នេះ ។

៤-ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋ ត្រូវណែនាំឱ្យមានការចងបដាពាក្យស្លោកនៅតាមក្រសួង ស្ថាប័ន អង្គភាពរដ្ឋគ្រប់លំដាប់ថ្នាក់ និងសហគ្រាស គ្រឹះស្ថានឯកជន យ៉ាងតិចចំនួនបី មានជាអាទិ៍ គឺ:

- **ជយោ! ព្រះរាជាណាចក្រកម្ពុជា**
- **អបអរសាទរខួបអនុស្សាវរីយ៍លើកទី ១២៣ នៃទិវាពលកម្មអន្តរជាតិថ្ងៃទី០១ឧសភា**
- **ខិតខំបង្កើនផលិតភាពការងារ គុណភាពផលិតផល ដើម្បីជំនះការលំបាកនានារបស់ប្រទេសជាតិ ។**

រាជធានី និងខេត្តទាំងអស់ ត្រូវជ្រើសរើសផ្លូវវិថីសំខាន់ៗ និងទីតាំងរោងចក្រ សហគ្រាស ការដ្ឋាន កសិដ្ឋាន ដើម្បីធ្វើការចងបដាពាក្យស្លោក ។

៥-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមដោះស្រាយថវិកាឱ្យបានទាន់ពេលវេលា និងតាមគោលការណ៍កំណត់ ដើម្បីធានាការចាត់ចែងដំណើរការរៀបចំឱ្យបានសមស្របតាមគោលបំណង និងសំណូមពរ ។

រាជរដ្ឋាភិបាលកម្ពុជា សូមអំពាវនាវដល់មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ កម្មករនិយោជិតកម្ពុជា និងពលករបរទេសទាំងអស់ ចូលរួមអបអរសាទរទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៩ ក្នុងក្តីសោមនស្សរីករាយ សាមគ្គីភាព និងភាតរភាព ដើម្បីឱ្យស័ក្តិសមជាបុណ្យការងាររបស់ប្រទេសជាតិយើង ដែលជាសមាជិកសហគមន៍អន្តរជាតិនានា នៅក្នុងពិភពលោក ។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធររាជធានី ខេត្ត ត្រូវរៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*

*-គ្រប់ក្រសួង ស្ថាប័ន*

*-អភិបាលរាជធានី ខេត្ត*

*-រាជកិច្ច*

*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៧ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩

# សារាចរណែនាំបន្ថែម

## ស្តីពី

## កិច្ចបញ្ជិការវដ្តទេយ្យបុរេប្រទាននៅតាមក្រសួង-ស្ថាប័ន និងមន្ទីរ-អង្គភាពនៅខេត្ត-រាជធានី

ដើម្បីអនុវត្តកិច្ចបញ្ជិការវដ្តទេយ្យបុរេប្រទាននៅតាមក្រសួង-ស្ថាប័ន និង មន្ទីរ-អង្គភាពនៅខេត្ត-រាជធានី អោយបានស្របទៅតាមទិសដៅនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអោយមានការឯកភាពទូទាំងប្រទេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំនូវចំណុចមួយចំនួនបន្ថែមលើសារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការចំណាយតាមនីតិវិធីវដ្តទេយ្យបុរេប្រទាន និងសារាចរណែនាំបន្ថែមលេខ ០០៣ សហវ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៧ ដូចខាងក្រោម៖

**ក-នៅថ្នាក់ជាតិ៖**

-វដ្តទេយ្យករបុរេប្រទាន និងវដ្តទេយ្យករបុរេប្រទានរងនៅនាយកដ្ឋាន ឬ ការិយាល័យ ដែលទទួលបន្ទុកការងារគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រសួង-ស្ថាប័ន ដែលបានបង្កើតវដ្តទេយ្យបុរេប្រទាន និងបានតែងតាំងវដ្តទេយ្យករបុរេប្រទានរួច ត្រូវចុះកិច្ចបញ្ជិការវដ្តទេយ្យបុរេប្រទាន ទៅតាមខ្លឹមសារនៃសារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការចំណាយតាមនីតិវិធីវដ្តទេយ្យបុរេប្រទាន។

-ដោយឡែក ចំពោះអាជ្ញាធរ មន្ទីរពេទ្យ សាលារៀន ម្ចាស់គម្រោង ឬ អង្គភាពផ្សេងៗទៀត ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ហើយដែលពុំទាន់បានបង្កើតវដ្តទេយ្យបុរេប្រទាន និងតែងតាំងវដ្តទេយ្យករបុរេប្រទាន គឺគ្រាន់តែកាន់បញ្ជីបេឡា បង្កើតប័ណ្ណចំណូលយោងតាមប័ណ្ណចំណាយដែលវដ្តទេយ្យករបុរេប្រទានផ្តល់ជូន បង្កើតប័ណ្ណចំណាយដោយផ្អែកតាមគោលការណ៍ចំណាយ និងវិក័យប័ត្រ ដែលមានការឯកភាពពីប្រធានអង្គភាព និង ធ្វើរបាយការណ៍ចំណាយតាមជំពូក គណនី អនុគណនី ដែលបានចំណាយ ដោយបញ្ជាក់ពីលេខប័ណ្ណចំណាយ និងថ្ងៃ-ខែ-ឆ្នាំ ព្រមទាំងបរិយាយអោយបានច្បាស់លាស់ រួចផ្ញើជូនទៅវដ្តទេយ្យករបុរេប្រទានថ្នាក់លើ។ ចំពោះប័ណ្ណចំណាយត្រូវចុះហត្ថលេខាដោយប្រធានគណនេយ្យ និងប្រធានអង្គភាព ឬ ប្រធានគម្រោង ហើយត្រូវដាក់លេខរៀងទៅតាមអង្គភាពនីមួយៗ។

-រដ្ឋទេយ្យករបុរេប្រទាន ក្រោយពីបានទទួលសក្ខីប័ត្រ និងរបាយការណ៍ចំណាយរួច គឺពុំចាំបាច់កត់ត្រាលំអិតនៅក្នុងបញ្ជីបេឡា ឬ ទិន្នានុប្បវត្តិសៀវភៅធំទៀតទេ ព្រោះកិច្ចបញ្ជិកានេះបានអនុវត្តនៅពេលប្រគល់ថវិកាជូនទៅអាជ្ញាធរ អង្គភាព មន្ទីរពេទ្យ សាលារៀន និងម្ចាស់គម្រោងរួចហើយ គឺគ្រាន់តែកត់ត្រាឥណពន្ធ គណនីលេខ ៤៧.២ និងឥណទាន គណនីលេខ ៤៧.៣ នៅពេលដែលបានបញ្ជូនលិខិតយុត្តិការដើម្បីបោះផ្សាយអាណត្តិនិយ័តកម្ម ។

-នាយកដ្ឋាន ឬ ការិយាល័យដែលទទួលបន្ទុកការងារគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវធ្វើការកាត់ស្តុកឥណទានរួម ហើយរដ្ឋទេយ្យករបុរេប្រទានត្រូវធ្វើការកាត់ស្តុកឥណទានរដ្ឋទេយ្យបុរេប្រទាន ។

-នៅពេលបានទទួលដីកាអមបញ្ចេញអាណត្តិបើកប្រាក់ពីអគ្គនាយកដ្ឋានរតនាគារជាតិវិញ រដ្ឋទេយ្យករបុរេប្រទានត្រូវកត់ត្រាឥណពន្ធគណនីលេខ ៥៩ និងឥណទានគណនីលេខ ៤៧.២ ។

- នៅរាល់ដំណាច់ខែនីមួយៗ រដ្ឋទេយ្យករបុរេប្រទានត្រូវបង្កើតតារាងតុល្យភាពរដ្ឋទេយ្យបុរេប្រទានរួមប្រចាំខែ ។

-ការទូទាត់ប្រាក់រដ្ឋទេយ្យបុរេប្រទាន ត្រូវភ្ជាប់មកជាមួយនូវៈ

+អាណត្តិនិយ័តកម្ម ចំនួន ០១ ( មួយ) ច្បាប់

+ដីកាអមបញ្ចេញអាណត្តិបើកប្រាក់និយ័តកម្ម ចំនួន ០៣ ( បី) ច្បាប់

+ដីកាអមលិខិតយុត្តិកា ចំនួន ០១ ( មួយ) ច្បាប់ ( រៀបរាប់លិខិតយុត្តិការភ្ជាប់តាម)

+សលាកប័ត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ ទៅតាមអនុគណនីនីមួយៗ ដែលមានលើអាណត្តិបើកប្រាក់និយ័តកម្មចំនួន ០១ ( មួយ) ច្បាប់

+តារាងតុល្យភាពរដ្ឋទេយ្យបុរេប្រទានប្រចាំខែ ចំនួន ០១ ( មួយ) ច្បាប់

+ប័ណ្ណចំណាយ ដែលចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ ( ប័ណ្ណថតចំលង) ចំនួន ០១ ( មួយ) ច្បាប់

+ប័ណ្ណចំណាយ ដែលចេញដោយរដ្ឋទេយ្យករបុរេប្រទានផ្តល់ជូនអង្គភាពបន្ត ( អាជ្ញាធរ មន្ទីរពេទ្យ សាលារៀន ម្ចាស់គម្រោង ឬ អង្គភាពផ្សេងៗទៀត) ( ប័ណ្ណថតចំលង) ចំនួន ០១ ( មួយ) ច្បាប់

+ប័ណ្ណចំណាយជាក់ស្តែង ដោយមានភ្ជាប់មកជាមួយនូវគោលការណ៍ចំណាយ និងវិក័យប័ត្រ

+របាយការណ៍ចំណាយមានបញ្ជាក់លេខប័ណ្ណចំណាយ ថ្ងៃ-ខែ-ឆ្នាំ និងបរិយាយទៅតាមអនុគណនី នីមួយៗ ចំនួន ០១ ( មួយ) ច្បាប់

-មូលដ្ឋាននៃការផ្ទៀងផ្ទាត់តួលេខរវាងរដ្ឋទេយ្យករបុរេប្រទាន ជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ គឺត្រូវពិនិត្យលើសមតុល្យៈ

+សម្រាប់ថវិកាមិនមែនកម្មវិធីគណនីលេខ ៥៤៣ នៅអគ្គនាយកដ្ឋានរតនាគារជាតិ ជាមួយគណនីលេខ ៥៩.០១ នៅសាមីក្រសួង-ស្ថាប័ន

+សម្រាប់ថវិកាតាមកម្មវិធីគណនីលេខ ៥៤៤ នៅអគ្គនាយកដ្ឋានរតនាគារជាតិ ជាមួយគណនីលេខ ៥៩.០២ នៅសាមីក្រសួង-ស្ថាប័ន ។

**ខ-នៅថ្នាក់ក្រោមជាតិ:**

-រដ្ឋទេយ្យករបុរេប្រទាន ដែលបំពេញការងារនៅតាមមន្ទីរជំនាញនីមួយៗ ត្រូវបង្កើតបញ្ជីចំណាយទៅតាមថ្នាក់ដូចតទៅ:

+បញ្ជីចំណាយសម្រាប់មន្ទីរជំនាញផ្ទាល់

+បញ្ជីចំណាយ ដែលផ្តល់ជូនការិយាល័យតាមស្រុក-ខណ្ឌ-ក្រុង ឬ អង្គភាពផ្សេងៗទៀតក្រោមឱវាទ

+បញ្ជីចំណាយ សម្រាប់ការិយាល័យស្រុក-ខណ្ឌ-ក្រុង និងអង្គភាពផ្សេងៗទៀតក្រោមឱវាទរបស់មន្ទីរជំនាញ

+បញ្ជីចំណាយ ដែលការិយាល័យស្រុក-ខណ្ឌ-ក្រុង ផ្តល់ជូនអង្គភាពជំនាញក្រោមឱវាទ (សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព ។ល។)

+បញ្ជីចំណាយ ដែលអង្គភាពជំនាញក្រោមឱវាទ ការិយាល័យស្រុក-ខណ្ឌ-ក្រុងចំណាយផ្ទាល់

-រដ្ឋទេយ្យករបុរេប្រទាន ត្រូវកាន់កិច្ចបញ្ជិកាគណនេយ្យរដ្ឋទេយ្យបុរេប្រទានទៅតាមមន្ទីរជំនាញខេត្ត-រាជធានីនីមួយៗ។ ដោយឡែក អង្គភាពផ្សេងៗទៀត ដែលស្ថិតក្រោមឱវាទរបស់មន្ទីរជំនាញខេត្ត-រាជធានី ដូចជាការិយាល័យស្រុក-ខណ្ឌ-ក្រុង ឬ អង្គភាពផ្សេងៗ (មន្ទីរពេទ្យ សាលារៀន ។ល។) ហើយនៅពុំទាន់បានបង្កើតរដ្ឋទេយ្យបុរេប្រទាន និងពុំទាន់បានតែងតាំងរដ្ឋទេយ្យករបុរេប្រទានទេនោះ គឺពុំចាំបាច់កាន់កិច្ចបញ្ជិកាគណនេយ្យរដ្ឋទេយ្យបុរេប្រទានទេ គឺគ្រាន់តែកាន់បញ្ជីបេឡា បង្កើតបញ្ជីចំណូលយោងតាមបញ្ជីចំណាយ ដែលរដ្ឋទេយ្យករបុរេប្រទានផ្តល់ជូន ហើយត្រូវបង្កើតបញ្ជីចំណាយ ដោយផ្អែកទៅតាមគោលការណ៍ចំណាយ និងវិក័យប័ត្រ ដែលមានការឯកភាពពីប្រធានអង្គភាព។

-ការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុង ត្រូវបង្កើតបញ្ជីចំណាយជូនអង្គភាពក្រោមឱវាទ ដែលនៅពុំទាន់បានបង្កើតរដ្ឋទេយ្យបុរេប្រទាន និងពុំទាន់បានតែងតាំងរដ្ឋទេយ្យករបុរេប្រទាន។ អង្គភាពក្រោមឱវាទ ការិយាល័យ ជំនាញស្រុក-ខណ្ឌ-ក្រុង (សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព ។ល។) គឺគ្រាន់តែកាន់បញ្ជីបេឡា និងបង្កើតបញ្ជីចំណូលយោងទៅតាមបញ្ជីចំណាយដែលការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុងផ្តល់ជូន ដោយត្រូវបង្កើតបញ្ជីចំណាយយោងទៅតាមគោលការណ៍ចំណាយ និងវិក័យប័ត្រ ដែលមានការឯកភាពពីប្រធានអង្គភាព និងត្រូវធ្វើរបាយការណ៍ចំណាយតាមជំពូក គណនី អនុគណនី ដែលបានចំណាយ ហើយត្រូវបញ្ជាក់ពីលេខបញ្ជីចំណាយ ថ្ងៃ-ខែ-ឆ្នាំ ព្រមទាំងបរិយាយអោយបានច្បាស់លាស់ រួចផ្ញើជូនទៅការិយាល័យជំនាញ ស្រុក-ខណ្ឌ-ក្រុង។

-ការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុង ត្រូវធ្វើការបូកសរុបរបាយការណ៍ ដែលបានទទួលពីអង្គភាពក្រោមឱវាទ ជាមួយរបាយការណ៍ចំណាយរបស់ខ្លួនផ្ទាល់ រួចបញ្ជូនមកមន្ទីរជំនាញខេត្ត-រាជធានី ដោយភ្ជាប់ជាមួយនូវសក្ខីប័ត្រ ដែលបានចំណាយផ្ទាល់ (បញ្ជីចំណាយ គោលការណ៍ចំណាយ និងវិក័យប័ត្រ) ព្រមទាំងបញ្ជីចំណូល-ចំណាយ របាយការណ៍ចំណាយ គោលការណ៍ចំណាយ និងវិក័យប័ត្ររបស់អង្គភាពក្រោមឱវាទ។

-រដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរងនៃមន្ទីរជំនាញខេត្ត-រាជធានី ក្រោយពីបានទទួលរបាយការណ៍ និងសក្ខីប័ត្ររបស់ការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុងហើយ គឺពុំចាំបាច់ធ្វើការកត់ត្រាក្នុងបញ្ជីបេឡា និងទិន្នានុប្បវត្តិសៀវភៅធំទៀតទេ ព្រោះកិច្ចបញ្ជិកាត្រូវបានអនុវត្តនៅពេលប្រគល់ថវិកាជូនទៅការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុងរួចហើយត្រូវធ្វើការកត់ត្រាឥណពន្ធគណនីលេខ ៤៧.២ និងឥណទានគណនីលេខ ៤៧.៣ នៅពេលដែលបញ្ជូនលិខិតយុត្តិកាដើម្បីបោះផ្សាយអាណត្តិបើកប្រាក់និយ័តកម្ម។ មន្ទីរជំនាញខេត្ត-រាជធានី ត្រូវធ្វើការកាត់ស្តុកឥណទានរួមហើយរដ្ឋទេយ្យករបុរេប្រទាន ត្រូវកាត់ស្តុកឥណទានរដ្ឋទេយ្យបុរេប្រទាន។ រដ្ឋទេយ្យករបុរេប្រទាន កត់ត្រាឥណពន្ធគណនីលេខ ៥៩ និងឥណទានគណនីលេខ ៤៧.២ នៅពេលដែលទទួលបានដីកាអមបញ្ចេញអាណត្តិបើកប្រាក់ពីរតនាគារខេត្ត-រាជធានីវិញ។ នៅដំណាច់ខែនីមួយៗ រដ្ឋទេយ្យករបុរេប្រទានត្រូវបង្កើតតារាងតុល្យភាពរដ្ឋទេយ្យបុរេប្រទានប្រចាំខែ។

-ការទូទាត់រដ្ឋទេយ្យបុរេប្រទានត្រូវភ្ជាប់មកជាមួយនូវៈ

+អាណត្តិបើកប្រាក់និយ័តកម្ម ចំនួន ០១ (មួយ) ច្បាប់

+ដីកាអមបញ្ចេញអាណត្តិបើកប្រាក់ ចំនួន ០៣ (បី) ច្បាប់

+ដីកាអមលិខិតយុត្តិកា ចំនួន ០១ (មួយ) ច្បាប់

+សលាកប័ត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ ទៅតាមអនុគណនីនីមួយៗ ដែលមានលើអាណត្តិបើកប្រាក់និយ័តកម្ម ចំនួន ០១ (មួយ) ច្បាប់

+តារាងតុល្យភាពរដ្ឋទេយ្យបុរេប្រទាប្រចាំខែ ចំនួន ០១ (មួយ) ច្បាប់

+ប័ណ្ណចំណាយ ដែលចេញដោយរតនាគារខេត្ត-រាជធានី ចំនួន ០១ (មួយ) ច្បាប់ (ច្បាប់ថតចំលង)

+ប័ណ្ណចំណាយរបស់មន្ទីរជំនាញ និងការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុង ចំណាយផ្ទាល់

+ប័ណ្ណចំណាយ ដែលមន្ទីរជំនាញផ្តល់ជូនទៅការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុង ឬ អង្គភាពផ្សេងទៀតក្រោមឱវាទ (ច្បាប់ថតចំលង់) ចំនួន ០១ (មួយ) ច្បាប់

+ប័ណ្ណចំណាយ ដែលការិយាល័យស្រុក-ខណ្ឌ-ក្រុង ផ្តល់ជូនទៅអង្គភាពក្រោមឱវាទ (សាលារៀន មណ្ឌលសុខភាព ឬ មន្ទីរពេទ្យ) (ច្បាប់ថតចំលង) ចំនួន ០១ (មួយ) ច្បាប់

+គោលការណ៍ចំណាយ និងវិក័យប័ត្រ របស់មន្ទីរជំនាញខេត្ត-រាជធានី និង ការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុង ចំណាយផ្ទាល់ ចំនួន ០១ (មួយ) ច្បាប់

+របាយការណ៍ចំណាយរដ្ឋទេយ្យបុរេប្រទានរួមចំនួន ០១ (មួយ) ច្បាប់

-ចំពោះប័ណ្ណចំណាយ និងសក្ខីប័ត្ររបស់អង្គភាពផ្សេងៗទៀត ក្រោមឱវាទរបស់ការិយាល័យជំនាញ ស្រុក-ខណ្ឌ-ក្រុង (សាលារៀន មន្ទីរពេទ្យ ឬ មណ្ឌលសុខភាព) ដែលពុំទាន់បានបង្កើតរដ្ឋទេយ្យបុរេប្រទាន និងតែងតាំងរដ្ឋទេយ្យករបុរេប្រទាន គឺត្រូវរក្សាទុកនៅមន្ទីរជំនាញខេត្ត-រាជធានី ហើយរង់ចាំការធ្វើសវនកម្មជាក្រោយ ដោយអាជ្ញាធរមានសមត្ថកិច្ច។

-មូលដ្ឋាននៃការផ្ទៀងផ្ទាត់តួលេខ រវាងរដ្ឋទេយ្យករបុរេប្រទានជាមួយនឹងរតនាគារខេត្ត-រាជធានី គឺត្រូវពិនិត្យលើសមតុល្យគណនី ដូចខាងក្រោម:

-សំរាប់ថវិកាមិនមែនកម្មវិធី : គណនីលេខ ៥៤៣ (នៅរតនាគារខេត្ត-រាជធានី) ជាមួយគណនីលេខ ៥៩.០១ (នៅមន្ទីរខេត្ត-រាជធានី)

-សំរាប់ថវិកាតាមកម្មវិធី : គណនីលេខ ៥៤៤ (នៅរតនាគារខេត្ត-រាជធានី) ជាមួយគណនីលេខ ៥៩.០២ (នៅមន្ទីរខេត្ត-រាជធានី) ។

ចំពោះអង្គភាពស្ថិតក្រោមឱវាទរបស់ក្រសួង-ស្ថាប័ននៅថ្នាក់កណ្តាល ក៏ដូចជាអង្គភាព ឬ ការិយាល័យ ដែលនៅក្រោមឱវាទរបស់មន្ទីរជំនាញខេត្ត-រាជធានី ឬ ការិយាល័យស្រុក-ខណ្ឌ-ក្រុង ដែលបានបង្កើតរដ្ឋទេយ្យបុរេប្រទាន ឬបានតែងតាំងរដ្ឋទេយ្យករបុរេប្រទានរួច ត្រូវអនុវត្តកិច្ចបញ្ជិកាទៅតាមខ្លឹមសារនៃសារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦។

លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសារាចរណែនាំបន្ថែមនេះ ត្រូវចាត់ទុកជានិរាករណ៍។

ទទួលបានសារាចរណែនាំនេះ សូមគ្រប់ក្រសួង-ស្ថាប័ន នៅថ្នាក់ជាតិ និង មន្ទីរ-អង្គភាព នៅថ្នាក់ក្រោមជាតិ គោរពអនុវត្តអោយទទួលបានលទ្ធផលល្អប្រសើរ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>ចម្លងជូន:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"*
*-អគ្គនាយកដ្ឋានរាជកិច្ច "ដើម្បីផ្សព្វផ្សាយ"*
*-គ្រប់ក្រសួង-ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន*
*-គ្រប់ខេត្ត-រាជធានី "ដើម្បីអនុវត្ត"*
*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៣០៦ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **តាំង គី ឃាង ខូ អិលធីឌី**

**TANG KŒUR KHEANG Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 12686/08P** ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **គី ឃាង** ប្រធានក្រុមប្រឹក្សាភិបាល

លោក **តាំង ហ្វួតឆាយ** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៥៧៤ Eo ផ្លូវលេខ ១២៨ សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ- លក់គ្រឿងអគ្គិសនីគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស-សេវា[illegible]ទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដុះ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុនទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា និងត្រា

ចម ប្រសិទ្ធ

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

ស.ជ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៣០៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ដាន ហេង ខូ អិលធីឌី**

**DAN HENG CO., LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 12698/08P ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ដាន ហេង**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២១៩ ផ្លូវលេខ ១០៧ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម-តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -[illegible] និង ចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន [illegible]

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

គឹម_ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

កសន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៣០៨ ពណ.ចបព

ភ្នំពេញថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០០៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ស្តូន រីសសស៍**
**STONE RESOURCES Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 12700/08P** ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ឡៅ អ៊ុយឈេង** ប្រធានក្រុមប្រឹក្សាភិបាល
លោក **អ៊ិន លាងហ៊ត** អភិបាល
លោកស្រី **លាង អ៊ី** អភិបាល
លោក **ឡៅ ម៉ិនមករា** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៤ BE3 ផ្លូវលេខ ១១១ សង្កាត់អូរឬស្សីទី១ ខណ្ឌ៧មករា រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវ[illegible]ទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដុះ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

ស.ជ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៣០៩ ពណ.ចបព

ភ្នំពេញថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ស៊ីស្រ៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ខូ អិលធីឌី**
**C3 SECURITY ( CAMBODIA ) CO.,LTD**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 12704/08P** ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ខន សុផល**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៥០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៥៥ ផ្លូវលេខ ១១៣ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម :
-សេវាកម្មសន្តិសុខឯកជន
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់ផ្នែកពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ឃឹម ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ស.ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៣១០ ពណ.ចបព

ភ្នំពេញ ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០០៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហ្គោលដេន ប៊ុល ខូ អិលធីឌី**

**GOLDEN BULL Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 12699/08P ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ខុច អ៊ើរេន** ប្រធានក្រុមប្រឹក្សាភិបាល

លោក **អ៊ុច ដារ៉ាត** អភិបាល

លោក **ខុច អ៊ុយគុត** អភិបាល

លោកស្រី **HIN VIMOL** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២០៥ A ផ្លូវលេខ ១៩ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម :ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការដូលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ -ការដូសដុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវា[illegible]ក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និង ចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ៕

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

គឹម_ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍-ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

កសន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៣១១ ពណ.ចបព

ភ្នំពេញថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០០៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **បាវិត ហ្គោលដេន ហ្គេត**

**BAVET GOLDEN GATE Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 12705/08P ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ង៉ាក ឌីហ្សុក**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្លូវជាតិលេខ ១ ភូមិបាវិតកណ្តាល ឃុំបាវិត ស្រុកចន្ទ្រា ខេត្តស្វាយរៀង

៥- កម្មវត្ថុអាជីវកម្ម :
- -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
- -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
- -ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
- -ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
- -ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
- -មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
- -បើកសាលារៀន
- -ភ្នាក់ងារពាណិជ្ជកម្ម-តំណាងពាណិជ្ជកម្ម
- -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
- -សេវាផ្សាយពាណិជ្ជកម្ម
- -បោះពុម្ពផ្សាយ
- -ផលិតខ្សែភាពយន្ត វីដេអូ CD
- -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាកម្មនិទេសចរណ៍ ... ទំនិញ
- -សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
- -វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

គីម_ស៊ីថន

**<u>ចម្លងជូន</u>**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាខេត្តស្វាយរៀង
- មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង " មុខការ "
- ឯកសារ -កាលប្បវត្តិ

កសន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៣១៨ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **គ្រូហ្គឺរ អ៊ិនវេសមេន ខមភេនី លីមីធីត**
KRUGER INVESTMENT COMPANY LIMITED

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 12711/08P ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន :

| | | | |
|---|---|---|---|
| លោក | STEPHANUS NOTHNAGEL | " តតីយជន " | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក | JACQUES VERMEULEN | " តតីយជន " | អភិបាល |
| លោកស្រី | **ជីនីស្សម៉ារីល្វីស ឡូវ៉េន** | | អភិបាល |
| លោក | KADIR GUNDUZ | " តតីយជន " | អភិបាល |
| លោក | IAN ROBERT GARNETT | " តតីយជន " | អភិបាល |

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៨៧ ផ្លូវជាតិលេខ ៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម :
- -ពាណិជ្ជកម្មៈទិញ លក់ ផ្លាស់ប្តូរទំនិញ នីហ័រណ អាហារំណាទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
- -ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
- -ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង វិនិយោគលើចលនៈ និងអចលនៈទ្រព្យ
- -ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
- -មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
- -បើកសាលារៀន
- -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
- -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
- -បោះពុម្ពផ្សាយ
- -ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស-សេវាបញ្ជូន និងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ.

ស.ផ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
លេខ ៥៣២០ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០០៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ស៊ី ប្រូភើធី អិលធីឌី**
**SEA PROPERTY LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 12703/08P** ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **OISHI KEN TISELL** "តតិយជន" ប្រធានក្រុមប្រឹក្សាភិបាល
លោក **រឿន សំនៀង** អភិបាល
លោកស្រី **តឹក រដ្ឋា** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិវត្តបូព៌ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប ។

៥- កម្មវត្ថុអាជីវកម្ម :
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ដីធ្លី ផ្ទះសំបែង
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ទេសចរណ៍ : ហាងលក់វត្ថុអនុស្សាវរីយ៍ សណ្ឋាគារ ភោជនីយដ្ឋាន ម៉ាស្សា ទីភ្នាក់ងារទេសចរណ៍ ដឹកជញ្ជូនភ្ញៀវទេសចរ រមណីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD ។ល។

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ជ.ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ហត្ថលេខានិងត្រា

**គឹម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាខេត្តសៀមរាប
- មន្ទីរពាណិជ្ជកម្មខេត្តសៀមរាប "មុខការ"
- ឯកសារ -កាលប្បវត្តិ

ស.ជ